# ការសម្ភាសរបស់ទូច ស៊ីថា

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ទូច ស៊ីថា

កៈ ចាស!អ៊ុំជាដំបូងសូមជំរាបសួរអ៊ុំ!

ខៈ ចាស!សូមជំរាបសួរ!

កៈ ចាស!អ៊ុំថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងមកធ្វើការសំភាសន៍ដល់អ៊ុំស្រីផ្ទាល់ ហើយខ្ញុំបានធ្វើការស្មាគចិត្តរបស់ខាងសាលាBYU នៅសហរដ្ឋអាមេរិកចឹងណាអ៊ុំ!

ខៈ ចាស!!

កៈ ហើយគំរោង១នេះហើយចឹងខាងសាលារៀនមួយនឹងបានតំរូវអោយធ្វើការសំភាសន៍ដល់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី៣៥ឆ្នាំអំពីប្រវត្តិរបស់គាត់ អំពីបទពិសោធន៍ការងារនឹងមានទាំងបទពិសោធន៍ជីវិតរបសគាត់ដែលបានមានបទពិសោធន៍តាំងពីតូចមកនឹងរហូតមកដល់ឥឡូវនឹងតើគាត់មានបទពិសោធន៍អ្វីគេខ្លះហើយពីមុនមកដល់ឥឡូវនឹងតើគាត់មានជីវិតយ៉ាងម៉េចខ្លះតើគាត់បាននឹងឆ្លងកាត់នូវបទពិសោធន៍ជីវិតរបស់គាត់នឹងមកនឹងមានបានឆ្លងកាត់បទពិសោធន៍ល្អៗអ្វីគេខ្លះហើយនឹងបទពិសោធន៍ដែលអាក្រក់ៗរបស់គាត់ដែលបានឆ្លងកាត់នឹងមានអ្វីខ្លះចឹងណាអ៊ុំ!

ខៈ ចាស!!

កៈ ចាស!ចឹងហើយថ្ងៃនេះខ្ញុំសូមអនុញ្ញាតពីអ៊ុំដើម្បីនឹងធ្វើការថតសំលេងរបស់អ៊ុំនឹងធ្វើការផុសនៅក្នុងវេបសាយខាងសាលាអាមេរិកបានដែលឬទេអ៊ុំ?

ខៈ ចាស!អឺឥឡូវនឹងមានការនិយាយនឹងគឺនិយាយពីរឿងប្រវត្តិណាំក្មួយណោះ។

កៈ ចាស!

ខ៖
ដូចថាវាបានជួបនឹងការលំបានណាស់ហើយបើធ្វើការនិយាយទៅចំទៅដូចថាជីវៈភាពវាលំបានណាក្មួយស្រីណាចឹងហើយបានថាជីវិតរបស់អ៊ុំនឹងមានការលំបាកច្រើនណាស់។ តាំងពីដើមនឹងខ្ញុំបានមានគ្រួសារចឹងទៅវាចេះតែបានធូធានឹងដែលចឹងណាស់ប៉ុន្តែក្រោយមកនឹងគាត់បានស្លាប់បាត់ទៅខ្ញុំនឹងចេះតែមានការដូចជារកស៊ីខ្លួនឯងដើម្បីនឹងធ្វើការងារចិញ្ចឹមជីវិតដូចជាមានការស៊ីឈ្នួលទៅអោយគេហើយមានទាំងទៅដើរប៉េះនេះនោះអោយគេសំរាប់ហូបចឹងទៅហើយកាលនឹងខ្ញុំនឹងបានទៅធ្វើការងារអនាម័យអោយគេនឹងនៅឯផ្ទះសំណាក់នឹងគេ
ឯណោះហើយបានបន្ទាប់ទៀតមកនឹងខ្ញុំបានធ្វើការងារលក់ដូរនៅទីនេះណាក្មួយស្រីដូចថាជីវៈភាពយើងនឹងវារាងថាអត់ចឹងណាក្មួយស្រីសំរាប់ទៅយកអោយថ្លៃផ្ទះរបស់គេដែលខ្ញុំបានជួលសំរាប់នៅនឹងដែលមានតំលៃនៅក្នុង១ខែនឹង១១០$អានឹងបូកទាំងថ្លៃផ្ទះទាំងថ្លៃទឹកនឹងថ្លៃភ្លើងអីនឹង។
ចាសហើយខ្ញុំបានធ្វើការលក់ដូរនឹងនៅក្នុងសាលារៀននឹងវាពិបាកណាស់គេដេញប៉ុន្មានដងហើយណាក្មួយស្រី។

ក៖ ហូយ!

ខ៖ នឹងហើយ!

ក៖
ចាស!ចឹងជាដំបូងនឹងខ្ញុំសូមអនុញ្ញាតដើម្បីនឹងធ្វើការសួរទៅអ៊ុំស្រីសិនថាតើអ៊ុំស្រីមានការអនុញ្ញាតដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៍អ៊ុំហើយធ្វើការថតសំលេងរបស់អ៊ុំស្រីដែលឬទេអ៊ុំ?

ខ៖ ក្មួយស្រីអត់មានអីណាហេស អត់មានអីណាក្មួយ?

ក៖
អត់មានជាប់ពាក់ពន្ធ័នឹងបញ្ហានយោបាយឬក៏បញ្ហាផ្សេងៗអីនោះទេគឺគ្រាន់តែការសំភាសន៍១នឹងគេគ្រាន់តែចង់ក្រងឯកសារទុកនូវប្រវត្តិរបស់អ៊ុំស្រីផ្ទាល់សំរាប់នឹងទុកអោយកូនចៅរបស់អ៊ុំនឹងអ្នកជំនាន់ក្រោយទៀតនឹងគេបានស្តាប់ថាកាលពីជំនាន់មុននឹងដែលជាជំនាន់របស់អ៊ុំស្រីនឹងកាលនឹងវាមានលក្ខណៈយ៉ាងណាដែលហើយពេលនឹងវាមានបានកើតឡើងយ៉ាងណាខ្លះ

ព្រោះអីពេលនឹងដូចថាអ៊ុំមានបទពិសោធន៍ជីវិតមួយដែលវាពិសេសដែលគេមិនធ្លាប់មានចឹង ហើយគេផ្សេងៗទៀតនឹងមិនបានធ្លាប់បានឆ្លងកាត់ដូចជាអ៊ុំនឹងចឹងហើយចឹងអ៊ុំជាអ្នកដែលមានហើយបានឆ្លងកាត់វាដោយផ្ទាល់ខ្លួនឯងចឹងហើយគេចឹងអោយអ៊ុំបាននិយាយនឹងប្រវត្តិរបស់អ៊ុំឡើង។

ខ៖ ចាស!!

ក៖

ចាស!ចឹងគេចង់ធ្វើការចង់ក្រងឯកសារនូវប្រវត្តិរបស់អ៊ុំពិកចឹងអ៊ុំមាននូវបញ្ហានឹងបទពិសោធន៍ជីវិតរបស់អ៊ុំនឹងមានអ្វីគេខ្លះដែលចឹងបើអ៊ុំមាននៅក្នុងជីវិតរបស់អ៊ុំណារឿងនឹងវាតែប៉ុណ្ណឹងនោះទេ

ខ៖

ចឹងឥឡូវនឹងក្មួយស្រីចង់និយាយអោយខ្ញុំនឹងចង់និយាយពីកាលនៅជំនាន់ពពតឬអី?កាលជំនាន់មុនឹងដែលខ្ញុំបានជួបកាលលំបាកមកនឹងអី?

ក៖ អត់ទេអ៊ុំដំបូងនឹងខ្ញុំត្រូវសួរអ៊ុំអំពីប្រវត្តិរបស់អ៊ុំដូចជាឈ្មោះ ថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំហើយពេលដែលអ៊ុំបានកើតមកនៅក្នុងគ្រួសារនឹងអ៊ុំមានបានជួបនឹងការលំបាកអ្វីគេខ្លះហើយហើយជីវៈគ្រួសាររបស់អ៊ុំនឹងមានជីវៈភាពយ៉ាងណាដែលចឹងណាអ៊ុំ។

ខ៖ ចាស!!

ក៖

ចឹងខ្ញុំនឹងធ្វើការសួរអ៊ុំនូវសំណួរជាបន្តបន្ទាប់មកទៀតក៏ប៉ុន្តែអ្វីដែលសំខាន់នឹងអ៊ុំគ្រាន់តែធ្វើការឆ្លើយនូវសំណួរដែលខ្ញុំបានសួរទៅអ៊ុំនឹងបានហើយចឹងពេលដែលខ្ញុំសួរអ៊ុំទៅអ៊ុំបានដឹងអ៊ុំឆ្លើយទៅវាបានទៅហើយ។

ខ៖ ចាសៗ!

ក៖ ចាស!

ខ៖ ចាស!ចឹងក្មួយស្រីនឹងបានសួរអំពីអាយុរបស់យាយឬក៏យ៉ាងម៉េចដែល?

ក៖
នូវទេអ៊ុំមុននឹងខ្ញុំបានធ្វើការសំភាសន៍នឹងគឺខ្ញុំបានសួរអ៊ុំថាតើអ៊ុំអនុញ្ញាតដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៍ដល់អ៊ុំស្រីដែលឬទេ?

ខ៖ ចាសបាន!

ក៖ ចាស!សូមអរគុណអ៊ុំចឹងថ្ងៃនេះគឺជាថ្ងៃទី១៥ ខែ ០៦ ឆ្នាំ២០១៨តែម្តង។

ខ៖ ចាស!!

ក៖
ចឹងអ៊ឺចឹងខ្ញុំបានធ្វើការសំភាសន៍ដល់អ៊ុំស្រីផ្ទាល់នៅថ្ងៃនេះចឹងហើយខ្ញុំសូមធ្វើការសំភាសន៍តែមុននឹងធ្វើការសំភាសន៍១នឹងខ្ញុំសូមសួរទៅដល់អ៊ុំស្រីវិញថាតើអ៊ុំស្រីមានឈ្មោះអ្វីដែរ?

ខ៖ ចាស!ខ្ញុំមានឈ្មោះថា ទូចស៊ីថាចាស។

ក៖ ចាស!ចឹងឈ្មោះរបស់អ៊ុំស្រិនឹងមានបានត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណដែលឬទេអ៊ុំ?

ខ៖ ចាស!បានត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណ។

ក៖ ចាស!ហើយទៅអ៊ុំមានឈ្មោះដែលបានហៅក្រៅដែលឬទេ?

ខ៖ អត់ទេក្មួយស្រីអើយឈ្មោះរបស់អ៊ុំនឹងគឺមានឈ្មោះនឹងតែម្តងនឹងគេហៅថាតែម្តង។

ក៖ អូ!!

ខ៖ អត់មានបានហៅក្រៅអីនោះទេ។

ក៖
អូ!ហើយចឹងឈ្មោះរបស់អ៊ុំពេញនឹងអ៊ុំមានឈ្មោះអ្វីដែលអ៊ុំមានឈ្មោះទូចស៊ីថានឹងតែម្តងនិង?

ខ៖
ចាស!ខ្ញុំមានឈ្មោះទូចស៊ីថានឹងតែម្តងនឹងឈ្មោះរបស់ខ្ញុំនឹងវាមានគេហៅនឹងតាំងពីដើមចឹង។

ក៖ ចាស!!

ខ៖ ចាស!ឈ្មោះនឹងមានតាំងពីដើមមកនឹងរហូតមកនឹងវាអត់មានបានអីក្រៅពីនឹងទេ។

ក៖ ចឹងអ៊ុំអត់មានបានធ្លាប់បានប្តូរអីនោះទេ?

ខ៖ ចាស!ខ្ញុំអត់មានអីធ្លាប់បានប្តូរអីនោះទេមានតែឈ្មោះនឹងតែម្តង។

ក៖ ហេសៗៗ

ខ៖ ហេសៗៗអត់មានបានធ្លាប់ប្តូរនោះទេ។

ក៖ ហើយអ៊ុំនរណាគេដែលបានដាក់ឈ្មោះនឹងអោយដល់អ៊ុំ?

ខ៖
ដូចជាឪពុកម្តាយរបស់ខ្ញុំនឹងគាត់បានដាក់ឈ្មោះនឹងអោយដល់ខ្ញុំតាំងពីខ្ញុំបាននៅក្នុងពោះគាត់តាំងពីខ្ញុំនៅតូចម្លេះហើយ
ចឹងណាហើយចឹងកាលនឹងតាំងពីដើមមកនឹងគេបានទៅធ្វើបញ្ជីជាតិ(បញ្ជីកំណើត)កាលនឹងគេបានធ្វើបញ្ជីជាតិនឹងដើម្បីនឹងធ្វើការកត់ថ្ងៃខែឆ្នាំកំណើតរបស់យើងដែលបានកើតនឹងមកណាក្មួយ
ហើយចឹងទៅបានជាគាត់បានដាក់ឈ្មោះនឹងមកហើយបានប្រើរហូតមកដល់សព្វថ្ងៃនឹងមកនឹង។

ក៖
អូចាស!ហើយចឹងតើគាត់មានបានថាតើឈ្មោះនឹងមានអត្តន័យឬក៏មានអ្វីដែលពិសេសដែលឬទេបានជាគាត់បានដាក់ឈ្មោះនឹងអោយដល់អ៊ុំ?

ខ៖
ចាស!និយាយទៅអោយចំនឹងឈ្មោះនឹងដូចថាពេលនឹងគាត់បានដាក់ឈ្មោះនឹងអោយនឹងដោយសារតែគាត់គិតថាប្រហែលជាឈ្មោះនឹងវាស្រួលហៅហើយបានជាគាត់ដាក់ឈ្មោះនឹងអោយនោះ។ហឹសៗៗ

ក៖ ចាស!!

ខ៖
ហើយគាត់ក៏បានថាដែលថាឈ្មោះនឹងកាលពីដើមមកនឹងគេហៅទៅវាស្រួលហៅនឹងចឹងហើយបានជាគាត់បានដាក់ឈ្មោះនឹងអោយមកនឹងនោះ វាមិនពិកបាកនឹង។

ក៖ ចាស!ហាមិនមែនអ៊ុំពូកែនិយាយទេអីបានជាគាត់បានដាក់ឈ្មោះនឹងអោយ?ហេស១១

ខ៖ ចាស!ក្មួយស្រីខ្ញុំសូមអរគុណហើយ។

ក៖ ហើយអ៊ុំសព្វថ្ងៃនឹងអ៊ុំមានទីលំនៅនៅឯណាដែលអ៊ុំ?

ខ៖ចាស!ខ្ញុំសព្វថ្ងៃនឹងខ្ញុំមានទីលំនៅនឹងនៅជិតពេទ្រលោកសង្ឃណាក្មួយស្រីខ្ញុំបានទៅជួលផ្ទះគេនៅនឹងណាក្មួយស្រី។

ក៖ អ៊ុំអាចធ្វើការបញ្ជាក់ទីតាំងបានដែលឬទេអ៊ុំនៅឯណាដែរ?

ខ៖ បើនិយាយទៅអោយចំទៅនឹងក្មួយស្រីអើយខ្ញុំមានទីលំនៅនឹងនៅក្នុងនោះ
មើលទៅឃើញមានអន្តែងដែលគេបានដាក់វានៅពីខាងលើនោះហើយគេបានដាក់វាឡើងនឹងហើយឃើញមានដំបូលរាងខ្ពស់នឹងជាងគេនឹងនោះផ្ទះរបស់ខ្ញុំហើយក្មួយស្រី។

ក៖ ចាស!!

ខ៖ វានៅជិតនឹងពេទ្រលោកសង្ឃយើងនឹងបើជិះទៅតែបន្តិចទៅដល់ឃើញហើយ។

ក៖ អូ!អ៊ុំនៅជិតនឹងពេទ្យលោកសង្ឃនៅក្នុងទួលគោកយើងនឹងនេះនឹង។

ខ៖ ចាស!!

ក៖ ចាស!អ៊ុំហើយទៅអ៊ុំមានស្រុកកំណើតនៅឯណាដែល?

ខ៖
ខ្ញុំមានស្រុកកំណើតរបស់ខ្ញុំនឹងគឺណេកស្រុកកំណើតរបស់ខ្ញុំនឹងអីបើនិយាយទៅអោយចំទៅនឹងខ្ញុំបានកើតនៅក្នុងភ្នំពេញនឹងទេតែពេលដែលបានបែកអាពតទៅនឹងខ្ញុំបានរត់ទៅនៅឯខេត្តកំពតហើយទៅខ្ញុំបានទៅនៅនឹងជាប់រហូតហើយរហូតមកដល់ពេលដែលតាខ្ញុំនឹងគាត់បានខូតចឹងទៅខ្ញុំនឹងក៏បាន

ដូចថាពេលនឹងណាខ្ញុំវាមិនបានដឹងថាខ្ញុំរកស៊ីអីនឹងចឹងហើយក៏ខ្ញុំនាំកូនរបស់ខ្ញុំនឹងមករកស៊ីនៅភ្នំពេញនឹងទៅ។

កៈ ចាស!ចឹងអ៊ុំសព្វថ្ងៃនឹងគ្រួសាររបស់អ៊ុំនឹងគាត់ទាំងអស់គ្នានឹងគាត់បាននៅជុំរុំគ្នាតើអ៊ុំនេស?

ខៈ គេបាននៅនឹងជុំរុំគ្នាតើគេបាននៅជាមួយនឹងមានកូនអាបងគេនឹងនឹងកូន៧គេ។

កៈ អ៊ុំមានកូនបានប៉ុន្មានដែរអ៊ុំ?

ខៈ ចាស!ខ្ញុំនៅសព្វថ្ងៃនឹងខ្ញុំមានកូនបាន៤នាក់នោះទេខ្ញុំមានកូនស្រី៣ប្រុស១នាក់។

កៈ គាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ?

ខៈ កូនទី១នាក់នឹងគាត់មានឈ្មោះថាអឺ... គេមានឈ្មោះថា ង៉េតមករា ង៉េតថាវី ង៉េតសំបូរ ហើយបន្ទាប់មកនឹងង៉េតគង្គា។

កៈ ស្រីមានប៉ុន្មាននាក់ហើយប្រុសមានប៉ុន្មានដែលទៅអ៊ុំ?

ខៈ ស្រី៣នាក់នឹងប្រុស១នាក់

កៈ
តើគាត់មានបានរៀបការមានគ្រួសារអស់ហើយឬនៅអ៊ុំគាត់បានរៀបការបានប៉ុន្មាននាក់ហើយ
?

ខៈ ឥឡូវនឹងគេមានគ្រួសារអស់ហើយ។ចាសបានរៀបការអស់ហើយ។

កៈ ចាស!!

ខៈ ចាស!គេបានរៀបការអស់ហើយកូនរបស់ខ្ញុំនឹង។

កៈ ចាស!តើគាត់មានមុខរបរជាអ្វីខ្លះទៅអ៊ុំ?

ខៈ កូនទី១នឹងគេបានលក់បបរនឹងហើយខ្ញុំ
នឹងគេបានទៅដើរលក់បបរដែលនឹងគេជាអ្នកធ្វើអាទេះសំរាប់លក់បបរនឹងណាក្មួយ។
ហើយកូនទី២នឹងគេបានចូលទៅធ្វើការនៅឯរោងចក្រ

។ហើយកូនទី៣នឹងគេបានធ្វើជាអ្នករត់កង់បីហើយ។ទី៤នឹងគេបានរត់តុការទាវអោយគេអីនឹង ចឹងណាចំពោះកូនទី៤អានឹងក្មួស្រី។

ក៖ ចាស!ហើយអ៊ុំអីចំពោះអ៊ុំប្រុសដែលគាត់ត្រូវជាស្វាមីរបស់អ៊ុំនឹងគាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះថា ង៉េត ស្វាយុក។

ក៖ តើគាត់មានស្រុកកំណើតនៅឯណាដែល?

ខ៖ ស្រុកកំណើតរបស់គាត់នឹងគាត់បានទៅនៅឯស្រុកឈូក។

ក៖ អូ!!

ខ៖ ឈូកនឹងនៅក្នុងខេត្តកំពតណា នៅក្នុងស្រុកកំពត។

ក៖ ចាស!ឈូកកំពត។

ខ៖ ហើយអ៊ុំបានរៀបការនឹងនៅក្នុងឆ្នាំណាដែល?

ក៖ ខ្ញុំបានរៀបការនឹងខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៧៩ ហើយការដូចជា១៩៧៨អីនឹងដែលខ្ញុំបានរៀបនឹងព្រោះអីពេលនឹងដូចថាខ្ញុំបានដូចជាបានរៀបនឹងបែកណាចាសនឹងដូចជា១៩៧៤នឹងហើយបានរៀបការនឹង១៩៧៣អីនឹងណាក្មួយស្រី ព្រោះអីនឹងខ្ញុំមានអាយុបាន៦២ឆ្នាំហើយ។

ក៖ ចាស!ចឹងអ៊ុំបានរៀបការនឹងនៅក្នុងសម័យមុនពពតណ៎អ៊ុំស្រី?

ខ៖ ចាស!

ក៖ ចាស!ចឹងអ៊ុំបានរៀបការនឹងតើឪពុកម្តាយគាត់ជាអ្នកដែលបានរៀបចំអោយឬក៏បានស្រលាញ់គ្នាដែលចិត្តនឹងចិត្តទេអ៊ុំស្រី?

ខ៖ ចាស!កាលដែលបានរៀបការនឹងគឺឪពុកម្តាយនឹងគាត់គឺជាអ្នកដែលបានរៀបចំទៅទេពួកគាត់បានជួយទុកដាក់អោយនឹងកាលនឹង

ចាសចឹងកាលនឹងបានរៀបការនឹងតាមប្រពៃណីទេណាហើយបន្ទាប់មកនឹងខ្ញុំបានរៀបការនឹងបាននឹងគាត់នឹងក៏បានធ្វើការគ្រូពេទ្យនៅឯចោមចៅយើងនឹងណាក្មួយស្រីគាត់បានធ្វើពេទ្រអើយនៅឯចោមចៅនឹងកាលនឹងគាត់បានបែកពីជំនាន់អាពតក៏បានរស់នៅជាមួយនឹងគ្នាមករហូតចឹងទៅរហូតបានបែកជំនាន់ពពតនឹងកាលនៅក្នុងសម័យពពតយើងនឹងជំនាន់១៩៧៩នឹងបានបែកហើយក្នុងឆ្នាំ១៩៨១អីនឹងបានគាត់បានស្លាប់នឹង។

ក៖ អូ!

ខ៖ នឹងហើយវារាងបានយូរដែលហើយ។

ក៖ ចាស!អ៊ុំគាត់បានកើតអីដែលអ៊ុំ?

ខ៖ គាត់មានជំងឺមហារីកថើម។

ក៖ អូ! សូមសោកស្តាយមែនទែនអ៊ុំ។

ខ៖ ចាស!!

ក៖ ចាស!ដល់ពេលនឹងចឹងទៅអ៊ុំពិតជាបានពិបាកចិត្តខ្លាំងហើយចឹងនោះ។

ខ៖
ចាស!កាលនឹងវាបានពិបាកខ្លាំងណាស់កាលនឹងនោះព្រោះអីកាលនឹងនោះខ្ញុំមិនបានជានឹងទៅរកស៊ីអីនោះទេក្មួយស្រីអើយខ្ញុំ
ហើយណាមួយនឹងកូននឹងវាបានរាងតូចៗនឹងចឹងហើយបានថាកាលនឹងដូចជាវាពិកបាកចឹងពេកហើយចឹងខ្ញុំនឹងក៏បានទៅនាំកូនៗនឹងមករស់នៅភ្នំពេញវិញចឹងទៅណាក្មួយស្រី។
ហើយកាលនឹងណាក្មួយស្រីអើយកាលនឹងខ្ញុំបានទៅស៊ីឈ្នួលអោយគេទៅស៊ីឈ្នួលអោយគេបានដើម្បីនឹងធ្វើការងាររៀបចំផ្ទះសំណាក់ ចឹងទៅចេះតែបានចឹងទៅណាសព្វនឹង។

ក៖
ចាស!ហើយចឹងអ៊ុំដែលពេលដែលអ៊ុំបានបន្ទាប់មកទៀតនឹងអ៊ុំបានដូចជាបានរៀបការជាមួយនឹងលោកពូហើយក៏បានមានគ្រួសារអីចឹងមកហើយទៅ

ខ៖ ចាស!!

ក៖ អីអ៊ុំបានធ្វើការងារអីគេទៀតខ្លះដើម្បីនឹងចិញ្ចឹមជីវិតរបស់អ៊ុំនឹងណា ។

ខ៖
និយាយទៅការងារអោយសព្វទៅនឹងវាមានការងារដែលដើរទៅស៊ីឈ្នួលអោយគេមានដើរទៅបោកខោអាវអោយគេចឹងទៅណាហើយខ្ញុំបានស៊ីឈ្នួលអោយគេទៅដាំបាយទៅគេទៅហើយពេលដែលខ្ញុំបានទៅស៊ី
ឈ្នួលដើម្បីនឹងដាំបាយអោយគេនឹងហើយទៅខ្ញុំក៏បានទៅធ្វើការងារអោយទៅជួយរៀបចំផ្ទះសំណាក់អោយគេបាន២ទៅ៣ឆ្នាំអីដែលចឹងទៅណាកាលនឹងនោះ
ហើយទៅពេលដែលខ្ញុំបានធ្វើការងានឹងហើយបានឈប់ទៅខ្ញុំនឹងក៏បានទៅធ្វើការងារអីអនាម័យនៅខាងខាត់អូយេ
ចឹងហើយទៅខ្ញុំក៏បានឈប់ទៅហើយពេលនឹងខ្ញុំមានបានដើមអីល្មមនឹងខ្ញុំក៏បានមកលក់ដូរអីចឹងទៅណាក្មួយស្រី។ ចាស

ក៖
ចាស!ហើយទៅអ៊ុំបានធ្វើការលក់នឹងអ៊ុំបានចាប់ផ្តើមលក់ដូរនឹងដូចជាមាននំបញ្ចុកខ្មែរយើងអីចឹងទៅណាអ៊ុំចឹងហើយនឹងតើអ៊ុំបានធ្វើការងារ១នឹងបានប៉ុន្មានឆ្នាហើយអ៊ុំ?

ខ៖ ក្មួយស្រី អ៊ុំបានលក់នឹងប្រហែលថាបានជាង២ឆ្នាំចុះដែលខ្ញុំបានលក់នឹងណាក្មួយស្រី។ ប្រហែលជាបាន២នឹងហើយចាស។

ក៖ ចឹងអ៊ុំលក់នឹងវាបានរាងយូរដែលហើយ។

ខ៖ ចាស!ក្មួយស្រី
ដូចក្មួយស្រីបានមើលទៅឃើញចឹងថាពេលដែលខ្ញុំបានលក់នឹងវាបានដូចជាបានជាង១០គីឡូរអីដេលនឹងណាក្មួយស្រី។

ក៖ ចឹងអ៊ុំលក់នឹងអ៊ុំបានលក់នឹងនៅក្នុងទីតាំងណាខ្លះដែល?

ខ៖
អត់ទេក្មួយស្រីខ្ញុំបានលក់នឹងដូចជាពេលដែលបានចាប់ផ្តើមលក់នឹងខ្ញុំបានចាប់ផ្តើមលក់នឹងខ្ញុំបានចាប់លក់នៅនឹងនេះតែម្តងនឹងក្មួយស្រីខ្ញុំមិនបានទៅលក់ទៅកន្លែងផ្សេងផង។

ព្រោះអីនឹងខ្ញុំអត់មានបានលក់ទៅកន្លែងផ្សេងផងខ្ញុំវាអត់មានកន្លែងដើម្បីលក់ចឹងហើយខ្ញុំលក់នៅនឹងនឹងបានចឹងហើយខ្ញុំក៏បានចាប់ផ្ដើមលក់នឹងនៅឯនឹងតែម្ដងចឹងទៅចាសក្មួយស្រី។ វាបានលក់នឹងបានជាប់មករហូតចឹងទោណាក្មួយស្រីអើយវាបានលក់នឹងបានជាប់មករហូតនឹងព្រោះអីខ្ញុំនឹងវាអត់មានដើមអីនឹងសំរាប់ទៅជួលគេអីនោះទេខ្ញុំមានតែបានលក់ទៅនឹងចឹងហើយបានជាវាមិនអស់លុយទៅជួលតូបគេអីទៀតណាក្មួយស្រី។ ចាសចឹងហើយខ្ញុំនឹងមិនទៅបានបើកន្លែងដើម្បីនឹងជួលគេទេមានដែលដូចថាពេលដែលយើងលក់បានចឹងទៅនឹងយើងលក់បានក្នុង១ថ្ងៃអីនឹងយើងលក់បានប្រហែលជាង៣០០០០រទៅ៤០០០០រដែរនឹងចឹងដែលទៅ។

ក៖ ចាស!

ខ៖
វាបាន១ថ្ងៃអត់១ថ្ងៃចឹងទៅវានឹងខ្ញុំដូចថាពេលនឹងខ្ញុំវាមិនទៅបានជួលគេទៀតនឹងណាក្មួយស្រី។

ក៖ ហេសៗ

ខ៖
ដូចថាខ្ញុំវាមិនទៅបានជួលកន្លែងគេទេព្រោះអីអត់មានលុយដើម្បីនឹងជួលគេទេណាក្មួយស្រី។

ក៖ ចាសអឺយ!
វាថ្លៃនោះចាសហើយចឹងអ៊ុំទីតាំងវិញអ៊ុំលក់នឹងមានទីតាំងនៅខាងមុខសាលាមាននៅមុននឹងបណ្ណាល័យហ៊ុនសែនដែលនៅនឹងមុខខាងសាលារៀនតែម្ដង។

ខ៖ ចាស!នឹងហើយក្មួយស្រីណា។

ក៖ ចាស!

ខ៖
និយាយទៅនឹងកាលមុនមកនឹងខ្ញុំវាមានការងារសំរាប់នឹងធ្វើតែឥឡូវនឹងខ្ញុំវាចាស់ណាស់ទៅហើយខ្ញុំវាអត់មានកិច្ចការអីទេខ្ញុំអត់ទាន់មានផ្ទះសំបែងអីចឹងទេណោក្មួយចឹងណាគេមិនទៅបានជួយយើងទៀតនោះទេចឹងណាក្មួស្រីណា។

តែសំរាប់រាល់ថ្ងៃនឹងខ្ញុំបានចង់ដែលខ្ញុំចង់សំរាប់នឹងទៅធ្វើការអីនឹងដែលនឹងព្រោះអីបើយើងធ្វើការងារទៅស៊ីឈ្នួលគេចឹងទៅយើងក៏វាបានមានប្រាក់ចំណូលអីខ្លះចឹងដែលនឹងហើយក៏វាបានធូរអីដែលតិចចឹងទៅណា។វាអីឥឡូវនឹងបើនិយាយទៅនឹងគេមិនទៅជួលយើងនឹងទៀតទេគេបាននឹងឈប់ជួលយើងហើយក្មួយស្រីអើយគេឈប់ជួលយាយហើយ។

ក៖ ចុះអ៊ុំចូលឆ្នាំនឹងតើអ៊ុំមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖ អឺបានចូលឆ្នាំនឹងខ្ញុំមានអាយុចូលឆ្នាំថ្មីនឹងខ្ញុំចូលអាយុបាន៦៣ឆ្នាំហើយ។ចាស

ក៖ តែអ៊ុំមើលទៅនៅក្មេងណាអ៊ុំហើយនៅសាច់ស្អាតណាអ៊ុំ។ហេសៗៗ

ខ៖ ហេសៗយាយនឹងបានចូល៦៣ឆ្នាំហើយនឹងក្មួយស្រីអើយ។

ក៖ ចាស!ចឹងអ៊ុំមានបានចាំចូលជាថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែលឬទេ?

ខ៖

ក្មួយស្រីអើយបើថាខ្ញុំបាននិយាយទៅអោយវាចំនឹងទៅវាគ្មានបានទៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងសោះប៉ុន្តែបើនិយាយទៅអោយវាបានចំទៅនឹងខ្ញុំនឹងបានកើតនៅក្នុងឆ្នាំមសាញ់។ចឹងខ្ញុំមានអាយុបាន៦០ជាងហើយណាក្មួយណាហើយបើនិយាយពីថ្ងៃខែឆ្នាំវិញនឹងដែលខ្ញុំបានកើតនឹងខ្ញុំមិនបានទៅចាំនោះទេក្មួយស្រីអើយចាស។ហេសៗៗ

ក៖ ប៉ុន្តែនៅក្នុងអត្តសញ្ញាប័ណ្ណរបស់អ៊ុំស្រីមាន?

ខ៖ ចាស!នៅក្នុងអត្តសញ្ញាប័ណ្ណនឹងមាន។

ក៖ ចាស!ចឹងហើយចុះអ៊ុំមានបានយកមកដែលឬទេ?

ខ៖ ខ្ញុំអត់បានយកមកទេអត្តសញ្ញាប័ណ្ណរបស់ខ្ញុំនឹងវាបាននៅផ្ទះ។ចាស

ក៖ ហើយបន្ទាប់មកទៀតនឹងខ្ញុំសូមសួរទៅអ៊ុំទៀតថាតើអ៊ុំមានបងនឹងប្អូនបានប៉ុន្មាននាក់ដែរ?

ខ៖ ចាស!ខ្ញុំមានបងប្អូន៧នាក់មានបានបងប្អូនប្រុស៤នាក់ហើយស្រីបាន៣នាក់ បងគេនឹងបានប្រុស ហើយបន្ទាប់មកខ្ញុំហើយបន្ទាប់មកទៀតនឹងបានប្រុស ប្រុសស្រីហើយបានប្រុសប្រុសនឹងបានជាប់គ្នា។

កៈ ចាស!ហើយទៅតើគាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ? ចាសបងប្អូនរបស់ខ្ញុំនឹងគាត់មានឈ្មោះអី។

ខៈ ចាស!បងប្អូនរបស់ខ្ញុំនឹងគាត់មានឈ្មោះថាសម សៀក ហើយចំណែកខ្ញុំនឹងមានឈ្មោះថា ស៊ីថា ហើយមានមីស្រីនឹងបន្ទាប់ខ្ញុំនឹងមានឈ្មោះថា សម សារិន សមសារុន សមចាន់ដារី សមសម្បត្តិ សមសម្ប។

កៈ ចាស!!

ខៈ អឹមប្រហែលជាស្លាប់អស់ទៅហើយមើលទៅព្រោះអីពេលដែលខ្ញុំ បាននឹងចេញមកនឹងដូចជាអត់មានដឹងដែលនឹងព្រោះអីពេលដែលបានបែកគ្នាហើយអត់មាន បងប្អូនណាគេបានមករកអីទេកាលនឹងហើយចឹង ខ្ញុំចេះតែហិយៗនឹងព្រោះអីអត់បានឃើញគាត់នឹងបានទាក់ទងនឹងអីអត់ដែលទេកាលនឹងដូច ជាពេលនឹងបានឈឺរហូតមកហើយចំណែកឯ ឪពុកម្ដាយអីនឹងមកតាំងពីសម័យសង្គមនឹងគាត់បានទៅអីគេបានឯកន្លែងបន្ទាយដោះគ្រជន នៅឯត្រពាំងក្រលឹងនោះក្នុយស្រីហើយខ្ញុំនឹងបាននៅឯអើយខ្ញុំនឹងបាននៅភ្នំពេញហើយចឹង ហើយបានជាពេលនឹងគាត់បានទៅតាមឪពុករបស់ខ្ញុំនឹងបាត់ទៅហើយចឹងបានថាពេលនឹងគា ត់បាននៅរកស៊ីឯនៅនឹងដល់ពេលចឹងទៅគាត់ក៏បានទៅរកស៊ីនៅជាប់អីផ្លូវនឹងចឹងដល់ពេលនឹ ងកាលនឹងខ្ញុំនឹងបាននឹកឃើញថាកាលនឹងប្រហែលជាគាត់នឹងវាមិននៅនោះទេកាលនឹង ព្រោះអីកាលនឹងវាបានបាត់ឈឹងទៅអស់នឹងចឹង។

កៈ កាលនឹងនៅក្នុងជំនាន់អាពតមែនអ៊ុំ?

ខៈ កាលនឹងវានៅក្នុងជំនាន់អីលុនណល។

កៈ អូល!

ខៈ កាលនឹងនៅជំនាន់លុនណលនឹងណាក្នុយស្រីដល់ពេលនឹងចឹងហើយពួកលុនណលនឹងវាបា នយកបាញ់នៅជាប់នឹងផ្លូវណាក្នុយស្រី។

កៈ ចាស!

ខ៖ នឹងហើយកាលនឹងគេបានយកមនុស្សនឹងទៅបាញ់ចោលនៅជាប់នឹងផ្លូវនឹងណាក្មួយស្រី។

ក៖ ចាស!!

ខ៖ នឹងហើយ

ក៖
ចឹងឪពុកម្តាយរបស់អ៊ុំកាលនឹងមិនមែននៅក្នុងជំនាន់ពពតទេកាលនឹងនៅក្នុងជំនាន់លុនណលវិញ។

ខ៖ ចាស!កាលនឹងវាមិនមែននៅក្នុងជំនាន់ពពតនោះទេវានៅក្នុងជំនានលុនណល។

ក៖ ចាស!ចឹងគាត់..

ខ៖ ចាស!ចឹងនៅក្នុងជំនាន់មុខអាពតនឹងនៅក្នុងជំនាន់លុនណលណាក្មួយស្រី។

ក៖ ហើយចឹងកាលនឹងអ៊ុំបានមើលឃើញគាត់បានស្លាប់នៅនឹងភ្នែករបស់អ៊ុំឬក៏យ៉ាងណាដែរ?

ខ៖
មិនទេកលានឹងខ្ញុំមិនទៅបានមើលឃើញគាត់នឹងបានស្លាប់នៅក្នុងសម័យជំនាន់ពពតនឹងទេកាលនឹងកាលនឹងដែលបានបែកហើយចូលជំនាន់នឹង១៩៧៩ហើយនឹងដែលបានបែកបាក់គ្នាអស់មកហើយនឹងវាបានបែកគ្នានឹងអស់ទៅបាត់ហើយព្រោះអីពេលនឹងដូចថាវាមិនបាននឹងសួររកគ្នាអីនោះទេណាក្មួយចាស។

ក៖ ចាស!ចឹងអ៊ុំមានបានធ្លាប់នឹងប្រកាសស្វែងរកបងនឹងប្អូនរបស់អ៊ុំដែរឬតេ?

ខ៖ អត់ទេខ្ញុំមិនដែលបានធ្លាប់បាន
ប្រកាសស្វែងរកបងប្អូនរបស់ខ្ញុំនោះទេអត់ដែលបានប្រកាសនោះទេដូចជាមានគេប្រកាសរកដែលនៅតាមប៉ុសទូរទស្សន៍អីនឹងណា

ក៖ ចាស!

ខ៖ ប៉ុន្តែខ្ញុំនឹងវាអត់មានដែលបានធ្លាប់នឹងប្រកាសអីនឹងគេនោះទេ។ ហើយខ្ញុំនឹងក៏ចេះតែថាដែលថាទៅប្រកាសសួររកបងនឹងប្អូនឹងបានដែលតែពី១ថ្ងៃទៅ១ថ្ងៃនឹងវាចេះតែនៅនឹងចឹងទៅ។

ក៖ ចេះខាតទៅ

ខ៖ចាស!ចេះតែចឹង

ក៖ ហើយចឹងអ៊ុំមានបានចង់ចាំអីទាក់ទងនឹងគាត់ដូចជាអ៊ុំមានបាននៅចាំមុខរបស់គាត់ រូបរាងរបស់គាត់ មាននៅសល់រូបថតនឹងសំលៀកបំពាក់របស់គាត់ដែលឬទេ?

ខ៖ ខ្ញុំបានបែកគ្នានឹងតាំងពីពេលដែលខ្ញុំនឹងមានអាយុបាន៦០ជាងហើយចឹងហើយនឹងវារាងភ្លេចខ្លះតែខ្ញុំបានចាំប្អូនប្រុសខ្ញុំនៅចាំប្អូនប្រុសទី៤ ខ្ញុំបាននៅចាំបានដែលគេនឹងនៅមានស្នាគស្នាមនៅនឹងកន្លែងនេះ។

ក៖ ចាស!គាត់មានស្នាគស្នាមនៅជិតនឹងស្មៀតផ្កានៅក្បាលរបស់គាត់នៅខាងឆ្វេង។

ខ៖ ចាសៗពេលនឹងគេមានស្នាមនឹងដោយសារពេលនឹងគេបានរត់ទៅនឹងវាបានរត់ទៅដួលហាស ហើយពេលដែលបានរត់ទៅដួលនឹងវាបាននៅជាប់ស្នាមនៅត្រង់នឹងវានៅជាប់នៅត្រង់នឹងអានឹងខ្ញុំវានៅបានចាំបាន។តែបើថាប្អូនស្រីវិញនឹងមួយនឹងដូចថាពេលនឹងខ្ញុំដូចជាបាននឹងរកដែលប៉ុន្តែរកដូចជាវាមិនទៅបាននៅចំឈ្មោះនឹងអីចឹងទៅមាននាមត្រកូលដែលគេបានរស់នៅត្រង់នេសអីចឹងទៅអានឹងបាននេសចឹងទៅណាក្មួយស្រីណាហើយបើថាមុខគាត់នឹងខ្ញុំបានចាំអីនឹងខ្ញុំអត់បានទៅចាំមុខរបស់គាត់នោះទេព្រោះអីវា៦០ឆ្នាំកាលដែលបានបែកគ្នានឹងនោះ ហើយបើនិយាយទៅអោយវាចំទៅនឹងតាំងពីកាលនឹងមកនឹងវាបានជាង៥០ទៅ៦០ឆ្នាំហើយនឹងណាក្មួយស្រីអើយ។

ក៖ ចាសៗ!

ខ៖ វាអត់បាននៅចាំ

កៈ ចាស!ចឹងកាលនឹងគេបានធ្វើការជំលៀសអ៊ុំស្រីនឹងទៅណាដែលកាលនឹង?

ខៈ
កាលនឹងពេលនឹងខ្ញុំបាននៅក្នុងភ្នំពេញយើងនឹងទេណាតែដល់ពេលក្រោយមកនឹងគេបានធ្វើការជំលៀសខ្ញុំនឹងបានទៅនៅនឹងឈូក នៅស្រុកខាងប្ដីខ្ញុំងនោះនៅក្នុងស្រុកឈូក។

កៈ ហឺ!ហើយគេបានប្រើអ៊ុំអោយធ្វើអ្វីគេខ្លះដែរកាលនឹង?

ខៈ កាលននៅក្នុងសម័យជំនាន់នឹងគេដូចជាបានប្រើខ្ញុំនឹងអោយបានទៅរែកដី ហើយគេប្រើអោយទៅរែកដីជីអាចម៍គោ អោយយើងទៅស្ទូងដីដកអីចឹងទៅនណាកាលនឹង។ ហើយក្មួយស្រីអើយកាលនឹងគេបានប្រើយើងនឹងអោយទៅស្ទូងស្រូវធ្វើស្រែហើយគេបានប្រើអោយយើងទៅទៅលើសំណាបអីចឹងដែលនឹងកាលនឹងគេអោយយើងបានទៅបោកស្រូវអីដែលនឹងកាលនឹងកាលនៅជំនាន់នឹងណា។

កៈ ចាស!!

ខៈ
ហើយចឹងកាលនឹងកាលដែលនៅក្នុងជំនាន់អាពតនឹងគេមានបានប្រើអ៊ុំអោយធ្វើអ្វីទេកាលនឹង?

កៈ
កាលនឹងបើនិយាយទៅអោយចំចឹងទៅកាលនឹងដូចថាគេបានប្រើយើងនឹងគេមិនទៅបានទៅវៃយើងហើយគេបានទៅចាប់យើងយកទៅចង់អីនោះទេកាលនៅក្នុងសម័យនឹងណាគេគ្រាន់តែបានប្រើយើងនឹងទៅរែកដីកាលនពីយប់ចឹងទៅរហូតដល់ម៉ោង១២ ចឹងទៅហើយក៏មានពេលខ្លះនឹងម៉ោង១អីហើយគេបានអោយយើងទៅបានទៅហូបបបរ១កូនចានចឹងទៅហើយយើងត្រូវទៅរែកដីពីថ្ងៃនឹងរហូតមកដល់ពេលល្ងាចអីនឹងបានជាគេបានអោយយើងនឹងបានមកវិញវាចឹង។ហើយពេលខ្លះទៅពេលដែលខែស្ទូងនឹងយើងគេអោយងើបនៅម៉ោង២អីចឹងទៅសំរាប់ទៅស្ទូងនឹងដកអីចឹងទៅណាក្មួយរហូតទាល់តែម៉ោង១១ទៅ១២នឹងបានបានហូប ។

កៈ ហូស! ហើយចឹងគេបានអោយរបបអាហារអោយដលល់អ៊ុំបានប៉ុន្មានពេលដែរ?

ខ៖ក្នុង១ថ្ងៃនឹងគេបានអោយយើងនឹងបានហូបបាន២ពេលដែលនឹងតែគេនឹងបានវែលអាចានគោមគេនឹងអោយយើងតែបន្តឹងគេក្មួយអើយចាស។
ហើយចឹងពេលដែលនិយាយទៅនឹងហូបវាមិនបានទៅឆ្អែតអីនឹងខ្ញុំបានធ្វើការលួចដកព្រលឹងអីសំរាប់យកទៅហូបដែលនឹងហាហាយកទៅដាក់ដាំអីសំរាប់ហូបនឹងយកទៅលាយអីចឹងទៅណាក្មួយស្រីហាហាហឹសៗៗ។មានត្នោតទុំអីនឹងក៏បានយកមកដោតពេលដេលវាទុំនឹងហើយយកវាមកដុតទៅអង្កៀមអីចឹងទៅណាក្មួយស្រីអើយ
ហឹសៗៗវារស់ដែលនឹងតែកាលនឹងវាបានរស់ឡើងពិបាកដែលនឹងបើកាលនឹងបងប្អូនជីដូនរបស់ខ្ញុំនឹងគាត់បានទៅណឹងគាត់បានស្លាប់បាត់ទៅអស់នៅតែខ្ញុំនឹងហើយនឹងគ្រួសាររបស់ខ្ញុំនឹងឯងកាលនឹង។
នៅតែម្តាយមីងមួយនាក់ទៀតនឹងតែដល់ពេលដែលបានបែកហើយនឹងគាត់ក៏បានឈឺហើយទៅក៏បានស្លាប់ទៅហើយមានបងប្រុសបងស្រីជីដូនមួយអីនឹងគាត់បានឈឺហើយស្លាប់ទៅអស់ហើយកាលនឹងដូចថាពេលនឹងវាឈឺដោយសារតែវាបានបាក់ចឹងណាកាលនឹងដូចថាវាបានបាកនឹងដោយសារតែវាអត់មានអីសំរាប់នឹងហូបនឹងទៅណា។

ក៖
ចុះកាលនឹងអ៊ុំមិនបានពិសារនឹងមិនសូវបាយគ្រាប់គ្រាន់ចឹងកាលនឹងអ៊ុំមានបានធ្លាប់ឈឺអីទេកាលនឹង?

ខ៖ ក្មួយស្រី
អើយកាលថ្ងៃណានឹងក៏ជាថ្ងៃដែលខ្ញុំបានកូសខ្យល់ដែលកាលននឹងដូចថាពេលដែលបានគេនឹងទៅប្រើនឹងអស់ដីរែក២ទៅ៣អំរែកចឹងទៅក្មួយស្រីហើយចឹងកាលនឹងគេក៏បានអោយយើងនឹងបានរែកតែ២ទៅ៣អំរែកទៀតហើយចឹងទៅជួនណាទៅក៏បានដួលនៅនឹងកន្លែងនឹងតែម្តងទៅកាលនឹងហើយនឹងចឹងកាលនឹងគេបានប្រើយើងចឹងហើយទៅយើងបានដួលនៅនឹងដីនឹងក៏បានធ្លាបមានដែលកាលនឹងដូចថាយើងនឹងវាមិនបានទៅដាំចំណាប់អីនឹងគេហាហា។

ក៖
ចាស!ចុះកាលនឹងគេមិនមានបានធ្វើបាបអីទេកាលនឹងនោះហើយចឹងកលានឹងគេមិនបាននឹងធ្វើបាបអ៊ុំហើយគេដែលអ៊ុំឈឺនឹងគេអត់មានបានអោយថ្នាំអីនឹងអោយអ៊ុំទេណ៎?

ខ៖
ហឺក្មួយស្រីអើយណាថ្នាំគ្រាប់នឹងវាមានហើយកាលនឹងនោះតែវាមានអាថ្នាំប្រភេទគ្រាប់អាប៊ិនមេដើងនឹងចឹងវាចេះតែទ្រនេះនឹងចឹងហើយគេចេះតែលេបទៅក្មួយស្រីអើយកាលនឹងវាចេះតែលេបចឹងទៅណាក្មួយស្រីអើយយើងនឹងចេះតែលេបនឹងទៅណាក្មួយស្រីអើយ។

ក៖ ចាស!

ខ៖ ហឺ!

ក៖
ចឹងអ៊ុំដូចជាពេលនឹងតើអ៊ុំស្រីបាននឹងនឹកចាំអ្វីជាងគេពេលដែលនៅក្នុងកាលសម័យអាពតនឹងតើអ៊ុំមានអ្វីគេដែលធ្វើអោយអ៊ុំចង់ចាំតែជាងគេនៅក្នុងសម័យនោះ?

ខ៖
ចាស!កាលនៅក្នុងសម័យនឹងកាលនឹងខ្ញុំវាមិនបាននេះអីទេកាលនឹងតែថាពេលនឹងខ្ញុំមានបងប្អូនខ្ញុំម្នាក់នឹងគេជាបងប្អូនរបស់ខ្ញុំនឹងផ្ទាល់តែម្តងនឹងណាស្រីគេបានយកទៅសំលាប់ចោលនឹងនៅនឹងភ្នែកតែម្តង់នឹងណាអាស្រី
គេបានសំលាប់នឹងខ្នងពូថៅនឹងក៏មានចំណែកឯបងប្អូនខ្ញុំនឹងគាត់បានមើលឃើញឡើងនឹងនៅនឹងភ្នែកមែនដែលវាបានយកទៅវៃចោលនៅឯស្រុកនឹងវាបានវៃនឹងខ្នងពូថៅអីនឹងនៅក្នុងនឹងហើយវាបានធ្វើទារុទាកម្មអីនឹងមែននឹងកាលនឹងណាក្មួយស្រីតែដូចថាកាលនឹងខ្ញុំនឹងវានៅរាងដូចថាវានៅរាងស្លុតណាកាលនឹងវាដូចថារាងស្លុតចិត្ត
ចឹងហើយនឹងគេបានធ្វើចឹងដាក់បងប្អូនខ្ញុំហើយអោយខ្ញុំឃើញនឹងភ្នែកស្រស់ៗនឹងណា។

ក៖ ចាស!

ខ៖ ហឺ!

ក៖ ចឹងកាលនឹងវាកំសត់ណាស់អ៊ុំវាទំរាំតែបានបែកពីជំនាន់នឹងមក។
ហើយចឹងពេលដែលអ៊ុំបានចេញបែកពីអាពតភ្លាមៗនឹងតើអ៊ុំមានបានយកអ្វីមកតាមខ្លួនដែរឬទេ?

ខ៖ ចាស!នឹងកាលនឹងខ្ញុំបានចេញមកនឹងខ្ញុំអត់មានបាននៅសល់អីនោះទេក្មួយស្រីអើយ ខ្ញុំមានសល់តែរបស់យើងនឹងដែលបានលាក់ទុកនឹងបានប្រហែលជា១ដំលឹងដែលនឹងកាលនឹងហើយជំនាន់នឹងខ្ញុំវាចេះតែបានទៅប្តូរយកអង្កគេហូបជាបន្តបន្ទាប់ទៅណាក្មួយអើយកាលនឹងនោះ។

ចឹងឯងកាលនឹងបើថាអោយនៅសល់របស់ទ្រព្យអីនឹងវាទាល់តែគេនឹងបានសល់កាលនៅពីនាយមកពីមុនៗមកនឹងបានគ្រាន់ជាបាននៅប្តូរហូបចឹងទៅគ្រាន់បានហូបចឹងទៅបានតែ១ហូបៗនឹងចឹងទៅខ្ញុំតែក្រោយមកនឹងតារបស់ខ្ញុំនឹងគាត់បានស្លាប់ទៅបាត់ចឹងទៅកាលនឹងខ្ញុំនឹងក៏បានធ្លាក់ខ្លួនចឹងទៅខ្ញុំនឹងវាមិនបានដឹងថានឹងទៅរកស៊ីស្អីនឹងនោះទេចឹងណាកាលនឹងវាលំបាកចឹងហើយខ្ញុំវាបានធ្លាក់ខ្លួនមកនចឹងខ្ញុំវាបានស្វាស់ស្វែងទៅរកបាយគេទៅបានបោកខោអាវអោយគេ

ហើយក៏បានធ្វើការអោយគេអីចឹងទៅណាក្មួយក៏បានទៅរៀបនឹងផ្ទះសំណាក់អីនឹងអោយទៅគេដែលនឹងណាក្មួយ។

ដើម្បីនឹងយកទៅអោយគេចឹងទៅរហូតដល់ពេលដែលខ្ញុំនឹងបានសន្សំលុយអីបាននឹងហើយបានជួលផ្ទះអីនឹងគេចឹងទៅណាពេលនឹង

ហើយក៏បានលក់ដូរអីបន្តិចបន្តួចចឹងទៅណាក្មួយស្រីនៅក្បែរសាលានឹងចឹងទៅណាក្មួយស្រី។

ក៖

ចាស!ចឹងសំរាប់ជីវិតរបស់អ៊ុំស្រីផ្ទាល់តើអ៊ុំស្រីមានបានធ្លាប់ការលំបាកអ្វីគេខ្លះតាំងពីតូចនឹងមករហូតមកដល់ឥឡូវនឹងតើអ៊ុំស្រីមានបានៅចាំអ្វីគេខ្លះដែរ?

ខ៖

កាលពីតូចនឹងមកនឹងខ្ញុំវារស់មិនបានស្ទូវជាពិបាកអីនោះទេកាលនៅក្នុងជំនាន់នឹងនោះតែវាបានលំបាកនឹងវានៅក្នុងជំនាន់នេះទេដែលវារាងពិបាកនឹងណាហើយនឹងកាលនឹងនៅក្នុងជំនាន់អាពតហើយពេលដែលប្តីនឹងគាត់បានស្លាប់ទៅនឹងខ្ញុំនឹងបានមានការលំបាក គឺមានការលំបាកនឹងខ្លាំងតែម្តងចាស។

ដូចថាកាលនឹងវាលំបាកនឹងដូចថាពេលខ្លះទៅនឹងវាអត់មានបានបាយហូបនឹងក៏មានដែរថាព្រោះអីនឹងបានអត់ពីប្តីអីចឹងទៅនឹងអត់ដឹងថាទៅរកស៊ីអីនោះទេដើម្បីនឹងធ្វើការចិញ្ចឹមកូនចឹងទៅណាក្មួយស្រី

ហើយចឹងពេលដែលបានមានបាយអីចឹងកាលនឹងបានដាំបាយនឹងហូបចែកកូនអីនឹងបានតិចៗអីចឹងទៅកាលនឹងនោះព្រោះអីកាលនឹងខ្ញុំគិតថាវាមិនកើតនោះទេបើខ្ញុំនឹងចេះតែស៊ីឈ្នួលអោយគេចឹងណា វាចឹងណាក្មួយស្រី។

ក៖ ចាស!

ខ៖ ខ្ញុំនឹងបានហែលការលំបាកនឹងវាបានច្រើនណាស់ច្រើនឆ្នាំមកហើយ
(មានសំលេងថៅគាត់នឹងនៅក្បែរនឹងគេបានស្រែថា គេៗៗៗ)
ចាសចឹងណាក្មួយស្រីអើយកាលនឹងវាលំបានណាស់វាមិនបានដឹងថាកាលនឹងវាទៅរកស៊ីស្អីនោះទេរហូតមកនឹង។
ហើយពេលនឹងបានដាក់ដាំបាយ១កំប៉ុងនឹងដាក់ដាំហើយបានបាយនឹងហូបជុំគ្នាដើម្បីនឹងយកទៅចែកអោយកូនៗនឹងបានហូបទៅចឹងទៅកាលនឹងនោះ។
ហើយដល់ពេលឥឡូវនឹងកូនរបស់ខ្ញុំនឹងគេក៏បានទៅស៊ីឈ្នួកគេដែលដល់ចឹងទៅគេបានរកបាននឹងគេក៏បានយកមកអោយបានខ្លះដែរចឹងទៅ
ហើយចឹងបានជាខ្ញុំនឹងបានរៀបធូខ្លះហើយឥឡូវនឹង។
កាលនឹងគេបានហៅខ្ញុំនឹងថាវាពិបាកមែនជីវិតនឹងនោះ។

ក៖ ហឺវាពិបាកណាស់ចឹងកាលនឹង

ខ៖ ចាស!

ក៖
ហើយចឹងកាលនឹងវាពិកបាកចឹងតាមបទពិសោធន៍ខ្លះនឹងពេលដែលអ៊ុំនៅកាលពីក្មេងៗនឹងតើអ៊ុំមានបានចូលចិត្តនឹងបានលេងល្បែងអីដែលឬទេកាលនឹង?

ខ៖
ចាស!ក្មួយស្រីអើយកាលនឹងខ្ញុំណាវាមិនទៅបានចេះលេងអីចឹងទេកាលនឹងនោះអើយអត់ចេះលេងទេល្បែងអីនឹងនោះ។

ក៖ ចាស!ចឹងអ៊ុំមិនបានចេះលេងល្បែងអីនោះទេកលានឹង?

ខ៖ ចាស!អត់មានបានចេះលេងអីនោះទេកាលនឹងនោៈ

ក៖ ហើយចុះអ៊ុំកាលនឹងមានល្បែងដូចជាអើយចោលឈូងអីនឹង?

ខ៖ អូ!កាលនៅពីក្រមុំនឹងកាលនឹងខ្ញុំចូលចិត្តលេង
ក្មួយស្រីកាលនឹងបានទៅលេងនៅពេលបានទៅវត្តអីនឹងកាលនឹងណាក្មួយស្រីនឹងកាលនឹងបានលេងឈូងអីនឹងដែរ។

ក៖ ចាសហឹសៗៗ

ខ៖ មានបោះអង្គុញអីចឹងដែលនឹងកាលនឹងនោះ។

ក៖ ហើយកាលនឹងអ៊ុំមានបានធ្លាប់នឹងចូលចិត្តស្តាបបទចម្រៀងអីដែលឬទេកាលនឹង?

ខ៖
ខ្ញុំអារឿងដែលថាបានស្តាប់អីនឹងខ្ញុំវាមិនសូវជាបានចូលចិត្តអីនឹងទេកាលនឹងនោះចាសហាហាៗៗ

ក៖ ចាស!បទចម្រៀងនឹង?

ខ៖
ចាស!បទចម្រៀងនឹងអត់សូវបានស្តាប់អីនោះទេកាលនឹងនោះខ្ញុំមិនបានស្តាប់អីច្រើននោះទេកាលនឹងពេលដេលខ្ញុំបានបើវាហើយស្តាប់នឹងបានត្រឹមតែ១បទទៅ២បទអីនឹងខ្ញុំបានបិទចេញហើយណាក្មួយស្រី។

ក៖ ហើយចឹងកាលដែលអ៊ុំនៅក្នុងសម័យមុន
នឹងមកនឹងពេលដែលអ៊ុំបានធំឡើងនឹងអ៊ុំមានក្តីប្រាថ្នាថាពេលដែលអ៊ុំធំឡើងនឹងអ៊ុំបាននឹងចង់ក្លាយជាអ្វីដែល?

ខ៖
ចាស!កាលពីជំនាន់មុននឹងបើនិយាយទៅអោយវាបានចំទៅនឹងក្មួយស្រីអើយកាលនឹងដូចថាខ្ញុំមានបំណាងចិត្តមួយដែលកាលនឹងដូចជាកាលនឹងខ្ញុំមានបំណាងចិត្តនឹង១ដែលកាលនឹងខ្ញុំចង់រៀនកាត់ដេរ។
កាលនឹងចង់ទៅកាត់ដេរនៅផ្សារគីឡូរលេខ៤យើងនឹងតែដល់ពេលក្រោយមកនឹងឪពុកខ្ញុំនឹង

គាត់បានចេះតែថាកុំអីព្រោះពេលនឹងគាត់នឹងជាអ្នកដែលរកស៊ីដែលនោះចឹងហើយគាត់ក៏បានប្រាប់មកខ្ញុំថាកូនអើយមិនបាច់នឹងទៅរកស៊ីអីនោះទេគិតតែពីខំប្រឹងរៀនចឹងទៅ។ ពេលនឹងគាត់បានប្រាប់ខ្ញុំថាខំប្រឹងរៀនឹងអោយតែចេះចឹងទៅ។ ហើយកាលនឹងបើរៀននឹងក៏រៀនវាមិនបានប៉ុន្មានដែលក្មួយស្រីអើយបើរៀនឹងបានរៀនត្រឹមថ្នាក់ទី២នឹង ហើយកាលនឹងរៀនដែរត្រឹមថ្នាក់ទី៧នឹងក៏បានបែកទៅកាលនឹងនោះចាសចឹងឯងចឹងហើយទោះបីកាលនឹងមានបំណងចង់រៀនដេរនឹងក៏មិនបានទៅរៀនដែរក្មួយស្រីអើយហាហា។

ក៖ ចាស!ចឹងអ៊ុំអាចនឹងចេះសរសេរអីបាន?

ខ៖ ចាស!ខ្ញុំអាចនឹងចេះសរសេរអីនឹងបានដែរណា ចេះអានអីនឹងក៏បានប៉ុន្តែក្មួយស្រីអើយបើការសរសេរវិញនឹងបើនិយាយទៅអោយចំទៅនឹងបើថាអោយសរសេរនឹងទាល់តែប្រើវេនតា ហើយបើថាអត់ពាក់វេនតានឹងអត់នឹងពាក់នឹងទៅវាមិនរួចដែលនឹង។

ក៖ ហើយកាលនៅក្នុងសម័យជំនាន់មានបានរៀនភាសាដែលឬទេអ៊ុំ?

ខ៖ កាលនៅសម័យជំនាន់នឹងគេបានរៀនតែជំនាន់បារាំងនោះទេ។

ក៖ ចុះអ៊ុំមានបានរៀនដែរឬទេ?

ខ៖
ខ្ញុំហេសនិយាយទៅអោយចំទៀតក្មួយស្រីអើយអត់បានរៀនអីនោះទេព្រោះអីកាបានលនឹងខ្ញុំបានរៀនចប់នឹងបានត្រឹមថ្នាក់ទី៧ហើយចឹងខ្ញុំរៀនវាមិនទាន់បានចប់ចឹងហើយបើថាកូនគេអ្នកមានអីចឹងគេបានទៅតែចំណែកខ្ញុំវិញនឹងវាខានរៀននឹងយូរហើយដែលនឹងហើយពេលនឹងរៀនបានតិចចឹងវាឥឡូវនឹងបានចេះអានអីនឹងតិចមើលបានដាច់អីនឹងដែរទេក្មួយស្រីណាអាចសរសេរអីបាន។

ក៖ ភាសាបារាំងមែនអ៊ុំ?

ខ៖ ភាសាបារាំងនឹងអ៊ុំចេះបានតិចៗទេ។

កៈ ហឹស !ហើយចឹងកាលនឹងសាលារៀននឹងនៅឯណាដែលអ៊ុំ?

ខៈ
កាលពីសម័យកាលពីដើមនឹងខ្ញុំបានរៀននៅសាលាដែលគេហៅថាបន្ទាយដោះក្រជលឯនោះ ក្នុយស្រីចាសខ្ញុំបានរៀននៅនោះ។ កាលនឹងខ្ញុំបានរៀននឹងអឺបានចូលរៀនត្រឹមថ្នាក់ទី៧ ហើយពេលរៀបានថ្នាក់ទី៦នឹងគេបានទៅរៀននៅឯកំពង់ស្ពឺ
ចឹងបានជារៀនដល់ថ្នាក់ទី៦នឹងគេបានអោយត្រលប់ទៅរៀននៅវិទ្យាល័យនៅឯកំពង់វិញណា ក្នុយស្រី។

កៈ ចាស!

ខៈចឹងបានត្រឹមតែថ្នាក់ត្រឹមថ្នាក់ទី៧ទេហើយបើទី៩ ទី១០ ទី៧នឹងបានចប់ហើយ ហើយបានមកអឺថ្នាក់ទី៦នឹងបានមកឯវិទ្យាល័យនៅកំពង់ស្ពឺ។

កៈ ចាស!អ៊ុំហើយចឹងកាលនឹងមូលហេតុអ្វីបានជាអ៊ុំបានរៀនត្រឹមថ្នាក់ទី៧ចឹង?

ខៈ កាលនឹងបានជាចឹងដោយសារតែវាបានបែកចូលក្នុងជំនាន់ឆ្នាំ១៩៧៥។

កៈ
អូ!ចឹងកាលនឹងអ៊ុំបានចូលរៀនត្រឹមថ្នាក់ទី៧នឹងហើយក៏បានបែកចូលជាជំនាន់អាពតនៅក្នុង ឆ្នាំ១៩៧៥?

ខៈ ចាស!

កៈ អូ!អ៊ុំឆ្នាំ១៩៧៩នឹងបានបែកពីអាពតវិញហើយអ៊ុំ។

ខៈ
អូ៎!នឹងហើយកាលនឹងក្នុងឆ្នាំ១៩៧៥កាលនឹងវាបានលឺដុងដែងណាក្មួយអើយចឹងហើយកា លនឹងខ្ញុំនឹងវាមិនហ៊ានរៀនទេខ្លាចវាម៉េចម៉ាទៅព្រោះអីវាឆ្ងាយពីផ្ទះយើង។

កៈ ចាស!អ៊ុំហើយចឹងកាលនឹងអ៊ុំមានអាយុប៉ុន្មានដែលកាលនឹង?

ខៈ កាលនឹងខ្ញុំដូចជាមានអាយុបាន១៣ឆ្នាំអីហើយ។

ក៖ ចាស!ចឹង១៣ឆ្នាំហើយ។

ខ៖ ចាស!១៣ឆ្នាំហើយកាលនឹង។

ក៖ ចាស!អ៊ុំហើយចឹងតើនៅក្នុងជីវិតរបស់អ៊ុំតើអ៊ុំមានបទពិសោធន៍ជីវិតល្អៗអ្វីគេខ្លះដែរ?

ខ៖
ហឹៗខ្ញុំនឹងណាក្មួយស្រីបើគិតពីក្មេងនឹងមកដល់ពេលឥឡូវនឹងអារឿងបទពិសោធន៍ល្អៗនឹងវាបានតិចជាងអារឿងពិបាកនឹងណាក្មួយស្រី
ព្រោះអីកាលនឹងដូចថាពេលដែលបានរៀបការអីហើយនឹងក៏បានរត់ចូលក្នុងជំនាន់អាពតទៅចាស
ហើយពេលដែលបានរត់ចេញពីជំនាន់អាពតនឹងមកនឹងក៏វានៅមិនទាន់បាននៅរាងធូធារអីដែលណាក្មួយស្រីវាមិនទៅបានមានអីទេចឹងហើយវាលំបាកទៀតនឹងពេលដែលតាខ្ញុំនឹងគាតបានឈឺស្លាប់ចឹងទៅវាលំបាកមកដោយគ្មានគាត់នឹងចឹងហើយទើបតែដល់ពេលឥឡូវនឹងទេដែលបានខ្ញុំនឹងវារាងបានធូធាជាងមុនព្រោះអីវាបានលក់អីតិចតួចចឹងទៅណាក្មួយស្រីចាសដូចថាខ្ញុំនឹងវាមានការលំបាកកំសត់ច្រើនវាពិបាកនឹងភាពងាយស្រួលនឹងជាងណាក្មួយស្រី។

ក៖ ចាសអ៊ុំ! ហើយទៅអ៊ុំមានបទពិសោធន៍របស់អ៊ុំផ្សេងទៀតដែលអ៊ុំចង់ធ្វើការបន្ថែមដែរទេអ៊ុំ?

ខ៖
ក្មួយស្រីអើយបើថានិយាយទៅអោយចំទៅនឹងក្មួយស្រីអើយមិនដឹងជាថានឹងចង់បានអ្វីនោះទេសព្វថ្ងៃនឹងអោយតែថាបាននឹងចិញ្ចឹមជីវិតនឹងយាយវាបានអរពេកទៅហើយក្មួយស្រីអើយ។

ក៖ ចាស!

ខ៖ ចាស!

ក៖
ចាស!ចឹងអ៊ុំមានពាក្យជាចុងក្រោយដើម្បីនឹងនិយាយដូចជាមានការផ្តែផ្តាំទៅដល់អ្នកដែលគេបានស្តាប់នឹងជាពិសេសទៅដល់កូនចៅរបស់អ៊ុំណា?

ខ៖
ចាស!ខ្ញុំសូមផ្ដែផ្ដាំដល់កូនក្មេងនៅជំនាន់ក្រោយទាំងអស់គ្នាថាអោយខំប្រឹងដូចជានៅក្នុងជំនាន់នឹងគេបានការជឿនលឿនមិនបានដូចនៅក្នុងជំនាន់របស់អ៊ុំ
ជំនាន់យាយដូចកាលពីមុននឹងវាពិបាកហើយមកដល់ឥឡូវនឹងដូចថាវាជាជំនាន់ដែលជឿនលឿនហើយវារាងបានធូធារហើយមានសុខសប្បាយហូរហៀរហើយវាបានសប្បាយចឹងណា

ក៖ចាស!

ខ៖ចាស!មានតែពាក្យប៉ុណ្ណឹងនោះទេ។

ក៖ ចាស!ចាស!អរគុណអ៊ុំច្រើនចាស។

ខ៖ ចាសៗ!